# អនុស្សរណៈនៃការយោគយល់ (MOU)
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការពលកម្មអន្តរជាតិ
# ស្តីពីកម្មវិធីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

តំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា (ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ -ក.វ.ក.) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) និងអង្គការពលកម្មអន្តរជាតិ(ILO) បានព្រមព្រៀងគ្នាបន្តអនុស្សរណៈនៃយោគយល់គ្នា (MOU) គ្រប់គ្រងកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការពលកម្មអន្តរជាតិបានចុះហត្ថលេខាដោយភាគីនៅក្នុងរាជធានីភ្នំពេញ ក្នុងខែធ្នូឆ្នាំ ២០១៣ (ឯកសារភ្ជាប់ ១) ខែធ្នូឆ្នាំ ២០០៨ (ឯកសារភ្ជាប់ ២) និងខែកក្កដាឆ្នាំ ២០១១ (ឯកសារភ្ជាប់ ៣) ។

យោងទៅលើការពិគ្រោះយោបល់គ្នារវាងភាគីពាក់ព័ន្ធពីអនាគត់នៃកម្មវិធីសហប្រតិបត្តិការបច្ចេកទេសបានដែលផ្តល់ឈ្មោះ*កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO* [1] ភាគីទាំងអស់មានបំណងធ្វើការបញ្ជាក់ជូនដូចតទៅ:

១ បន្តឆន្ទៈធ្វើការងាររួមគ្នា ដើម្បីធ្វើឲ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារនៅក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា តាមរយៈការអនុវត្តន៍ច្បាប់ការងារកម្ពុជា និងបទដ្ឋានការងារស្នូល ដែលបានទទួលស្គាល់ជាអន្តរជាតិ ។

២ បន្តគាំទ្រការអនុវត្តន៍កម្មវិធីសហប្រតិបត្តិការបច្ចេកទេស ដែលបានផ្តល់ឈ្មោះថាកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO អនុវត្តន៍លើសពីឆ្នាំ ២០១៣ រហូតដល់ចុងឆ្នាំ២០១៦ តាមរយៈការចូលរួមផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ពីរាជរដ្ឋាភិបាលកម្ពុជា ពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងពីអ្នកបញ្ជាទិញសំលៀកបំពាក់អន្តរជាតិ ដែលមានប្រភពដើមពីកម្ពុជា ផ្អែកលើតម្លៃនៃសេវាដែលផ្តល់ជូន ។

---

[1] កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO ត្រូវបានបង្កើតឡើងដោយអង្គការពលកម្មអន្តរជាតិកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេសមួយចំនួន ។ ការផ្តល់ហិរញ្ញប្បទានស្នូលនៃកម្មវិធីនេះបានមកពី CMB/00/52M/CMB (ការរួមចំណែករបស់ GMAC) CMB/00/M51/CMB (ការចូលរួមចំណែករបស់រាជរដ្ឋាភិបាលកម្ពុជា) និង CMB/06/03M/MUL (ថ្លៃចំណាយដែលអាចបានមកវិញពីអ្នកបញ្ជាទិញអន្តរជាតិ និងការចូលរួមរបស់សហគ្រាស តាមរយៈការវាយតម្លៃ សេវាប្រឹក្សា និងបណ្តុះបណ្តាល)។

## អាណត្តិការងារ

៣ គោលបំណង និងអាណត្តិ នៃកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO គឺដើម្បីជួយកសាងសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់កម្ពុជា តាមរយៈការអនុវត្តន៍ការវាយតម្លៃលើល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលផ្អែកលើច្បាប់ការងារកម្ពុជា និងបទដ្ឋានការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយរាយការណ៍ពីការរកឃើញរបស់ខ្លួនជាសាធារណៈ ដោយបញ្ជាក់លម្អិតពីការអនុលោមតាម ឬមិនអនុលោមតាមច្បាប់របស់រោងចក្រនីមួយៗ - ដែលខកខានមិនបានអនុវត្តន៍តាមតម្រូវការនៃច្បាប់ការងារកម្ពុជា និងបទដ្ឋានការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។ របាយការណ៍រកឃើញដោយរោងចក្រកាន់តែប្រសើរនៅកម្ពុជា មុនចេញផ្សាយជាសារធារណៈ នឹងត្រូវចែករំលែកការរកឃើញនោះជាមួយក្រសួងពាណិជ្ជកម្ម និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ រោងចក្រមានកំហុស មានពេលវេលា ៦០ថ្ងៃ ដោះស្រាយចំណុចខ្វះខាតនៅក្នុងរបាយការណ៍ ក្រោយការចេញផ្សាយរបាយការណ៍វាយតម្លៃរបស់រោងចក្រកាន់តែប្រសើរនៅកម្ពុជា។

៤ ខណៈពេលសកម្មភាពការត្រួតពិនិត្យរបស់កម្មវិធី គ្របដណ្តប់ដោយគោលការណ៍ដែលកំណត់នៅក្នុងប្រកាស (លេខ. ១០៨ ក.ព.ណ/M ២០០១ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៨ ខែមិនា ឆ្នាំ២០០១ ឬប្រកាស ដែលបានធ្វើបច្ចុប្បន្នភាព) ពាក់ព័ន្ធទៅនឹងឧស្សាហកម្មនាំចេញសំលៀកបំពាក់កម្ពុជា សកម្មភាពផ្តល់ការប្រឹក្សា និងការបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ ដើម្បីលើកកំពស់ផលិតភាព និងភាពប្រសើរឡើង នឹងត្រូវធ្វើឡើងដោយធម្មតាតាមមូលដ្ឋានសេវាយកកម្រៃទៅលើវិស័យឧស្សាហកម្មផ្សេងៗទៀត ដូចជា រោងចក្រស្បែកជើង និងសហគ្រាសឯកជនផ្សេងៗទៀតផងដែរ ។

## ការរៀបចំហិរញ្ញវត្ថុ

៥ ការរៀបចំហិរញ្ញវត្ថុបន្ថែមនេះ នឹងគ្របដណ្តប់រយៈពេលចាប់ពី ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ មានថវិការកាលាទិករណ៍សរុបចំនួន **៣,០៩៣,៩២០** ដុល្លារសហរដ្ឋអាមេរិក ។ គំរោងនេះនឹងត្រូវអនុវត្តន៍ស្របតាមច្បាប់ និងបទបញ្ញត្តិហិរញ្ញវត្ថុរបស់អង្គការ ILO ។

៦ គំរោងសហប្រតិបត្តិការបច្ចេកទេស រោងចក្រកាន់តែប្រសើរនៅកម្ពុជា ILO CMB/12/52/CMB (វិភាគទាន GMAC) និង CMB/12/51/CMB (វិភាគទានរាជរដ្ឋាភិបាល) CMB/12/01/REV (ថ្លៃជាវ និងថ្លៃបណ្តុះបណ្តាល) ទាំងអស់នឹងត្រូវបន្តរហូតដល់បំណាច់ឆ្នាំ២០១៦ នឹងត្រូវផ្តល់ហិរញ្ញប្បទានស្របទៅនឹងថវិកាប៉ាន់ស្មាន និងរូបមន្តខាងក្រោម ក្នុងករណីវិភាគទានត្រូវបានទទួលតាមសន្យា ។

| ប្រភពនៃមូលនិធិ | រូបមន្ត | ២០១៤ ចំណាយប៉ាន់ស្មាន | ២០១៥ ចំណាយប៉ាន់ស្មាន | ២០១៦ ចំណាយប៉ាន់ស្មាន | សរុប ចំណាយប៉ាន់ស្មាន |
|---|---|---|---|---|---|
| រាជរដ្ឋាភិបាលកម្ពុជា (RGC) | ជាការចូលរួមចំណែកដោយរាជរដ្ឋាភិបាលកម្ពុជា (ត្រូវបានគេស្គាល់ថាជា "ស្នូលរួមចំណែក ") នៅអត្រានៃ 0,00004 X តម្លៃនាំចេញសម្លៀកបំពាក់សរុបកាលពីឆ្នាំមុននៅក្នុងឆ្នាំ ២០១៤ និង 0,0000៤៥ នៅឆ្នាំ២០១៥ និងឆ្នាំ២០១៦ | ១៩៤,០០០ | ២៤៦,៦២៣ | ២៨១,១៥០ | ៧២១,៧៧៣ |
| សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) | ជាការចូលរួមចំណែកដោយ GMAC (ត្រូវបានគេស្គាល់ថាជាស្នូលរួមចំណែក) តម្លៃចំណាយប្រតិបត្តិការ និងការគាំទ្រសរុបប្រចាំឆ្នាំរបស់ BFC។ ការផ្តល់វិភាគទាន ១៤% តម្លៃចំណាយប្រតិបត្តិការ និងការគាំទ្រសរុបប្រចាំឆ្នាំរបស់ BFC ក្នុងឆ្នាំ ២០១៤ , ១៥% ក្នុងឆ្នាំ ២០១៥ និង ១៦% ក្នុងឆ្នាំ២០១៦។ | ២៦៦,២៤១ (១៤%) | ២៣៦,២៦៩ (១៥%) | ២៦៩,៦២៧ (១៦%) | ៧៧២,១៤៧ |
| អ្នកបញ្ជាទិញសំលៀកបំពាក់អន្តរជាតិ តាមរយៈថ្លៃការបណ្តុះបណ្តាល និងសេវាប្រឹក្សា | ជាការចូលរួមចំណែកដោយអ្នកទិញអន្តរជាតិ (ប៉ាន់ស្មាន)[2] និងតាមរយៈ ថ្លៃបណ្តុះបណ្តា និងសេវាប្រឹក្សា | ៤៥០,០០០ | ៥៥០,០០០ | ៦០០,០០០ | ១.៦០០,០០០ |
| សរុប | | ៩១០,២៤១ | ១.០៣២,៨៦២ | ១.១៥០,៧៧៧ | ៣.០៩៣,៩២០ |

[2] ចំណូលប៉ាន់ស្មានពីការលក់របាយការណ៍វាយតម្លៃ សេវាបណ្តុះបណ្តាល និងសេវាពាក់ព័ន្ធ ។

៧ វិភាគទានសួ្ចលរបស់ GMAC ជាក់ស្តែងនិងត្រូវគណនាជាប្រចាំឆ្នាំនិងបង់ប្រាក់ដោយផ្អែកលើកំណើនភាគរយនៃតម្លៃ ប៉ាន់ស្មានប្រតិបត្តិការ និងការគាំទ្រសរុបប្រចាំឆ្នាំរបស់ BFC ១៤% នៅក្នុងឆ្នាំ២០១៤ ១៥% នៅក្នុងឆ្នាំ២០១៥ និង ១៦% នៅក្នុងឆ្នាំ២០១៦។ វិភាគទាននឹងត្រូវបង់ចូលទៅក្នុងគណនីធនាគាររបស់អង្គការ ILO ដូចបានបង្ហាញខាងក្រោមជាពីរដំណាក់កាលស្មើគ្នា គឺនៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣០ ខែវិច្ឆកា នៃឆ្នាំបន្តបន្ទាប់ ។

៨ វិភាគទានសួ្ចលរបស់រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវផ្អែកលើការគណនាជាមេគុណ ០.០០០០៤ ដង នៃតម្លៃការនាំចេញឧស្សាហកម្មសំលៀកបំពាក់សរុបរបស់កម្ពុជាសំរាប់ឆ្នាំមុន សំរាប់ឆ្នាំ២០១៤ និង ០.០០០០៤៥ ដង សំរាប់ឆ្នាំ២០១៥ និងឆ្នាំ២០១៦ ។

៩ ការបង់ប្រាក់នឹងត្រូវបង់ទៅក្នុងគណនីធនាគារតាមលំដាប់

ឈ្មោះស្ថាប័នធនាគារ: ACELDA Bank Plc.

អាស័យដ្ឋានធនាគារ: #61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Cambodia

Account Name: International Labour Organisation

Account Number: 0001-01-200411-11

Currency: United State Dollars

១០ អ្នកទិញសម្លៀកបំពាក់អន្តរជាតិ មានប្រភពដើមមកពីប្រទេសកម្ពុជា ដែលបានប្រើរបាយការណ៍វាយតម្លៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការពលកម្មអន្តរជាតិ និងរោងចក្រដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគម្រោង BFC នឹងរួមចំណែកដល់ប្រតិបត្តិការកម្មវិធីដោយផ្អែកលើការបង់ថ្លៃសេវាដែលបានផ្តល់ជូន[3] ។

១១ ម្ចាស់ជំនួយបន្ថែមអាចផ្តល់ហិរញ្ញប្បទានដល់កម្មវិធីថវិកាដែលនឹងត្រូវបានដាក់បញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទូទៅនៃកម្មវិធីទៅគណៈកម្មាធិការប្រឹក្សាគម្រោងនេះ។ របាយការណ៍ហិរញ្ញវត្ថុទូទៅនឹងត្រូវបានផ្តល់ទៅឱ្យគណៈកម្មាធិការសម្រាប់ឆ្នាំប្រតិទិនគ្នានៅក្នុងខែមីនាឆ្នាំក្រោយនេះ ។

---

[3] រចនាសម្ព័ន្ធនៃថ្លៃសេវាសំរាប់រួមចំណែកវិភាគទានរបស់អ្នកបញ្ជាទិញត្រូវបានសម្រេចធ្វើឡើងជាប្រចាំឆ្នាំ ដោយអង្គការពលកម្មអន្តរជាតិ កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជាILO-BFC Programme និងការងារកាន់តែប្រសើរជាសកល ។

និរន្តរភាព

១២ ផ្អែកលើការពិភាក្សាថ្មីៗជាមួយដៃគូកម្មវិធី ដើម្បីបន្តនិរន្តភាពកាន់តែធំទូលាយក្នុងអំឡុងពេលពីឆ្នាំ ២០១៤-២០១៦ អង្គការ ILO និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC នឹងផ្តោតការយកចិត្តលើការកែលម្អប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងបង្កើតឡើងនូវថ្លៃចំណាយដែលអាចបានមកវិញផ្អែកលើថវិកា (more feasible cost recovery based budgeting) និងប្រព័ន្ធហិរញ្ញវត្ថុ ព្រមទាំងលើកកំពស់តួនាទីរបស់ដៃគូរតំរោងក្នុងការដឹកនាំ និងការគ្រប់គ្រងកម្មវិធី ។

របាយការណ៍

១៣ អង្គការពលកម្មអន្តរជាតិនេះនឹងផ្តល់នូវរបាយការណ៍និទានកថាមួយ ពីការរួមចំណែកវិភាគទានក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះ ។ របាយការណ៍វឌ្ឍនភាពការងារបច្ចេកទេស នឹងត្រូវបានផ្តល់ជូនពីរដងក្នុងមួយឆ្នាំ នៅថ្ងៃទី១៥ ខែកុម្ភៈ និងថ្ងៃទី១៥ ខែសីហា ជារៀងរាល់ឆ្នាំ ។ របាយការណ៍ហិរញ្ញវត្ថុដែលមានការវាយតម្លៃបញ្ជាក់នឹងត្រូវបានផ្តល់ប្រចាំឆ្នាំ នៅថ្ងៃទី៣០ ខែមេសា ជារៀងរាល់ឆ្នាំ ជាលក្ខណៈបុគ្គលទៅម្ចាស់ជំនួយនីមួយៗ អ្នកចាត់ការនៃកម្មវិធីនឹងរាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការប្រឹក្សាគម្រោង លើវឌ្ឍនភាពក្នុងការអនុវត្តន៍នៃកម្មវិធីនេះ ។

សេចក្តីផ្សេងៗ

១៤ រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមទទួលដោះស្រាយ និងទទួលខុសត្រូវចំពោះការប្តឹងតវ៉ា ឬវិវាទរបស់ភាគីទីបីណាមួយ ដែលកើតចេញពីប្រតិបត្តិការនានាដែលស្ថិតក្រោម MOU នេះ ប្រឆាំងទៅនឹងអង្គការពលកម្មអន្តរជាតិ ឬបុគ្គលិករបស់អង្គការនេះ ហើយការពារពួកគេមិនឲ្យមានគ្រោះថ្នាក់ (hold them harmless) ដែលទាក់ទងទៅនឹងការប្តឹងតវ៉ា ឬវិវាទនោះឡើយ។ ភាគីទាំងអស់នឹងពិភាក្សាជាមួយគ្នារកដំណោះស្រាយដែលសមស្របចំពោះការតវ៉ា ឬវិវាទកើតឡើងមកពីការធ្វេសប្រហែស ឬអកប្បកិរិយាមិនសមរម្យរបស់បុគ្គលិក ILO (willful misconduct of ILO employees)។

១៥ គ្មានប្រការណាមួយនៅក្នុង ឬទាក់ទងនឹងអនុស្សរណៈនៃការយោគយល់នេះ មាន ខ្លឹមសារផ្ទុយនឹងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលអង្គការពលកម្មអន្តរជាតិ (ILO) មាននោះឡើយ ។

ចុះហត្ថលេខាដោយ:

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**សមាគមរោងចក្រកាត់ដេរនៅកម្ពុជា**

Mr. Van Sou Ieng

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**អង្គការពលកម្មអន្តរជាតិ**

Mr. Maurizio Bussi

*ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០១៣*

**Memorandum of Understanding (MOU) between Royal Government of Cambodia, Garment Manufacturers Association in Cambodia and International Labour Organization on ILO Better Factories Cambodia Programme**

Representatives of the Royal Government of Cambodia (Ministry of Commerce and Ministry of Labour and Vocational Training – RCG), the Garment Manufacturers Association in Cambodia (GMAC), and the International Labour Organization (ILO) have agreed to extend the MOU governing the *ILO Better Factories Cambodia programme* signed by the parties in Phnom Penh in September 2005 (Attachment 1), December 2008 (Attachment 2), and July 2011 (Attachment 3).

In reference to consultations between the parties concerning the future of the ILO technical cooperation programme entitled *ILO Better Factories Cambodia programme* [1] the parties wish to state the following;

1 Their willingness to continue to work together to improve working conditions in the textile and apparel sector of Cambodia through the application of the Cambodian Labour Law and internationally recognized core labour standards;

2 Their support to continue the implementation of the ILO Technical Cooperation programme entitled *ILO Better Factories Cambodia programme* beyond 2013 until the end of 2016 through direct financial contribution from The Royal Government of Cambodia, the Garment Manufacturers Association in Cambodia (GMAC) and by the international garment buyers sourcing from Cambodia based on fees for services rendered.

Mandate

3 The aim and mandate of the *ILO Better Factories Cambodia programme* is to help to build the economy and competitiveness of Cambodia through performing assessments on the working conditions in garment factories based on Cambodian Labour Law and internationally recognized core labour standards, and to report on its findings publicly by detailing compliance and non-compliance of individual factories that fail to meet the legal requirements in Cambodian Labour Law and internationally recognized core labour standards. Better Factories Cambodia reports with findings intended for public disclosure will be shared with Ministry of Commerce and Ministry of Labour and Vocational Training. Non-compliant factories shall remedy the deficiencies in the report within 60 days upon issuance of Better Factories Cambodia assessment reports.

4 While the programme monitoring activities are governed by the principles set in the Prakas (No. 108 MoC / M 2001 signed March 28, 2001 or updated Prakas) concerning the Cambodian export garment industry, the advisory and training activities on workplace

[1] The ILO Better Factories Cambodia programme is composed of several ILO technical cooperation programmes. The core financing of the programme is derived from **CMB/00/52M/CMB (GMAC contribution), CMB/00/M51/CMB (Government Contribution) and CMB/06/03M/MUL (cost recovery from international buyers and participating enterprises from assessment, advisory and training services).**

improvement and productivity enhancement are operated regularly on a fee for service basis and can be made available for other industry sectors such as footwear factories, and individual enterprises as well.

Financial arrangements

5 This extension arrangement will cover a period from 1 January 2014 to 31 December 2016 with a total anticipated budget of US$ **3,093,920.** The project will be implemented in accordance with the ILO financial rules and regulations;

6 The *ILO Better Factories Cambodia* technical cooperation projects CMB/12/52/CMB (GMAC contribution) and CMB/12/51/CMB (Government Contribution), CMB/12/01/REV (Subscriptions and Training fees) will all be extended until the end of 2016 and financed in accord with the estimates and formulas below, provided that pledged contributions are received;

| **Source of Funds** | **Formula** | **2014 (est)** | **2015 (est)** | **2016 (est)** | **Total (est)** |
|---|---|---|---|---|---|
| Royal Government of Cambodia (RGC) | As contributed by Royal Government of Cambodia (to be known as 'core contribution') at the rate of 0.00004 x total previous year garment export value in 2014 and 0.000045 in 2015 and 2016 | 194,000 | 246,623 | 281,150 | 721,773 |
| Garment Manufactures Association of Cambodia (GMAC) | As contributed by GMAC (to be known as 'core contribution') as an increasing percentage of BFC's total estimated annual operation and support costs. The contribution will be 14% of BFC operation and support cost in 2014, 15% of BFC operation and support cost in 2015, and 16% of BFC operation and support cost in 2016 | 266,281 (14%) | 236,239 (15%) | 269,627 (16%) | 772,147 |
| International Garment Buyers and Training and Advisory fees | As contributed by international buyers (estimate)[2] and through training and advisory fees | 450,000 | 550,000 | 600,000 | 1,600,000 |
| **Total** | | **910,281** | **1,032,862** | **1,150,777** | **3,093,920** |

[2] Estimated revenue from sales of assessment reports, training and related services.

7 Actual GMAC core contributions will be calculated annually and paid based on an increasing percentage of BFC's annual estimated total operation and support costs: 14% in 2014, 15% in 2015, and 16% in 2016. The contribution should be paid into the ILO bank account as indicated below, in two equal instalments on 30th June and 30th November of the relevant year;

8 Actual RGC core contribution will be based on a calculation of 0.00004 times the total Cambodian garment industry export value for the previous year for 2014 and 0.000045 times for 2015 and 2016. It will be paid into the ILO bank account no later than 30th June of the relevant year.

9 Payments shall be made to the following bank account:

Name of the Banking Institution: ACLEDA Bank Plc.
Bank's Address: # 61, Preah Monivong Blvd., Sangkat Srah Chork,
Khan Daun Penh, Phnom Penh, Cambodia
Account Name: International Labour Organisation
Account Number: 0001-01-200411-11
Currency: United States Dollars

10 The international garment buyers sourcing from Cambodia who use the *ILO Better Factories Cambodia programme* assessment reports and factories that participate in BFC training courses will contribute to programme operation based on fees for services rendered[3];

11 Additional donors may provide financing to the programme the budgets of which will be incorporated in the general financial reporting of the programme to the Project Advisory Committee. A general financial report will be provided to the committee for each calendar year in March of the subsequent year.

Sustainability

12 Based on recent discussions with programme partners, pursuit of greater sustainability during 2014-2016, ILO and the International Finance Corporation (IFC) will concentrate on improving internal management systems, creating more feasible cost recovery based budgeting and finance systems, and enhancing the role of the project's partners in the leadership and governance of the programme.

Reporting

13 The ILO will provide a single narrative report for contributions made under this MOU. Technical progress reports will be provided twice a year on 15th February and 15th August of each year. Certified financial report will be provided yearly by 30th April of each year individually to each donor. The manager of the programme will regularly report to the

[3] The fee structure for buyer contributions is decided upon yearly by the ILO-BFC programme and Better Work Global.

Project Advisory Committee on the progress made in the implementation of the programme.

Miscellaneous

14 The RGC agrees to handle and be responsible for any third-party claim or dispute arising from operations under this MOU against the ILO or its employees and shall hold them harmless in respect of such claims or disputes. Where a claim or dispute arises from the gross negligence or wilful misconduct of ILO employees, the Parties will consult with a view to finding a satisfactory solution;

15 Nothing in this MOU or relating thereto shall be construed as a waiver of any of the privileges and immunities enjoyed by the ILO.

Signed by:

H. E. Sun Chanthol
Senior Minister
*Minister of Commerce*

Mr. Van Sou Ieng
*President of Garment Manufacturers Association of Cambodia*

H.E. Ith Sam Heng
*Minister for Labour and Vocational Training*

Mr. Maurizio Bussi
*Officer in Charge, ILO Country Office for Cambodia*

*December 18, 2013*